YUNNAN DAILY PRESS GROUP
No.158

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7670 ថ្ងៃសុក្រ ទី 29 ខែមិថុនា ឆ្នាំ 2018

## កុមារខ្មែរប្រាំមួយនាក់បានទទួលការព្យាបាលជំងឺបេះដូងនៅខេត្តយូនណាន



*គិលានុបដ្ឋាយិកាម្នាក់កំពុង តែត្រួតពិនិត្យ កុមារកម្ពុជាម្នាក់ ដែលកំពុងតែទទួលការព្យាបាល ជំងឺបេះដូងនៅមន្ទីរពេទ្យហ្វូវ៉ៃ ខេត្តយូនណាន (រូបថតដោយ Li Hengqiang )*

កុមារខ្មែរម្នាក់ដែលកំពុងទទួលការព្យាបាលជំងឺបេះដូងនៅខេត្តយូនណាន បានប្រាប់អ្នកកាសែតដោយមានស្នាមញញឹមលើមុខថា ខ្ញុំមិនខ្លាចវះកាត់ទេ ពីព្រោះខ្ញុំចង់ជាសះស្បើយក្នុងពេលឆាប់ៗ ហើយត្រឡប់ទៅផ្ទះវិញ! កុមារនេះមានអាយុត្រឹមតែប្រាំមួយឆ្នាំ មកពីខេត្តបាត់ដំបងនៃប្រទេសកម្ពុជា ។ នៅថ្ងៃទី២០ ខែមិថុនា កុមារនេះ និងកុមារខ្មែរប្រាំនាក់ទៀត ដែលមកពីខេត្តបាត់ដំបងបានទទួលការវះកាត់ដើម្បីព្យាបាលជំងឺបេះដូងតាំងពីកើតនៅមន្ទីរពេទ្យព្យាបាលជំងឺសរសៃឈាមបេះដូង ហ្វូវ៉ៃ ខេត្តយូនណាន ។

នៅខែធ្នូ ឆ្នាំ២០១៧ មន្ទីរពេទ្យហ្វូវ៉ៃ ខេត្តយូនណានបានចាត់បញ្ជូនគ្រូពេទ្យជំនាញចិនទៅប្រទេសកម្ពុជារួមសហការគ្នាជាមួយស្ថាប័នសុខាភិបាលនៃខេត្តបាត់ដំបង ដើម្បីពិនិត្យសុខភាពបេះដូងឱ្យកុមារខ្មែរ ១៣.១៤៧នាក់ ក្នុងសាលាបឋមសិក្សា និងសាលាមត្តេយ្យចំនួន២១ និងបានរកឃើញកុមារ២៦នាក់ ដែលមានជំងឺបេះដូងតាំងពីកើត ។ ក្នុងនោះកុមារប្រាំពីរនាក់បានទទួលការព្យាបាលជំងឺដោយឥតគិតថ្លៃនៅប្រទេសចិននាខែមករា ឆ្នាំ២០១៨នេះ ហើយបានត្រូវបញ្ជូនទៅស្រុកខ្មែរវិញ ។ នៅថ្ងៃទី៤ ខែមិថុនា ក្រុមអ្នកជំងឺទី២ បានត្រូវបញ្ជូនមកដល់ប្រទេសចិន ។

នៅពេលនិយាយអំពីសកម្មភាពសប្បុរសធម៌នេះ ម្តាយអ្នកជំងឺម្នាក់បានស្រក់ទឹកភ្នែក ហើយនិយាយថា សូមអរគុណគ្រូពេទ្យចិនដែលបានសង្គ្រោះជីវិតរបស់កូនខ្ញុំ ខ្ញុំពិតជាសប្បាយចិត្តយ៉ាងខ្លាំង!

លោក ម៉ា ជួន ជំនួយការប្រធានមន្ទីរពេទ្យ ហ្វូវ៉ៃ ខេត្តយូនណាន បានណែនាំថា គ្រូពេទ្យដែលធ្វើការវះកាត់ និងព្យាបាលជំងឺឱ្យកុមារខ្មែរទាំង២៦នាក់នោះ សុទ្ធតែជាគ្រូពេទ្យជំនាញល្បីឈ្មោះរបស់ប្រទេសចិន ។ ក្រោមការគាំទ្រពីស្ថាប័នពាក់ព័ន្ធមូលនិធិសប្បុរសធម៌ និងមន្ទីរពេទ្យយើងបានព្យាបាលជំងឺឱ្យកុមារខ្មែរដោយឥតគិតថ្លៃ។ ជាពិសេសមន្ទីរពេទ្យយើងខ្ញុំបានរៀបចំសកម្មភាពលេងកម្សាន្តដែលមានការចូលរួមពីកុមារាកុមារីចិន ហើយនាំកុមារខ្មែរទៅមើលសត្វរំពេ និងដើរលេងសួនផ្កា ដើម្បីធ្វើឱ្យពួកគេកាន់តែស្គាល់ទីក្រុងគុនមីង ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា អ្នកជំងឺខ្មែរក្រុមទី៣ នឹងត្រូវបញ្ជូនមកក្រុងគុនមីងនៅខែសីហាខាងមុខ ។ សកម្មភាពសប្បុរសធម៌នេះបន្តរៀបចំនៅពេលខាងមុខ ដើម្បីឱ្យកុមារខ្មែរមានសុខភាពបេះដូងកាន់តែល្អប្រសើរ ៕

**ដោយ លី ហឹងឈាំង**

## អ្នកសារព័ត៌មានខ្មែរជាប់ចិត្តទៅនឹងខេត្តយូនណានតាមរយៈពិព័រណ៍ចិន-អាស៊ីខាងត្បូង

ក្នុងឱកាសពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី៥ និងពិព័រណ៍ផលិតផលនាំចេញនាំចូលក្រុងគុនមីងលើកទី២៥ អ្នកសារព័ត៌មានដែលមកពីប្រទេសអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង រួមមានប្រទេសកម្ពុជា ឡាវ ថៃ មីយ៉ាន់ម៉ា វៀតណាម ហ្វីលីពីន បង់ក្លាដែស ឥណ្ឌា និងនេប៉ាល់ជាដើម បានជួបជុំគ្នានៅក្រុងគុនមីង ។ អ្នកសារព័ត៌មានកម្ពុជាបានយកកាមេរ៉ារបស់ខ្លួនថតទេសភាពដ៏ស្រស់ស្អាតរបស់ខេត្តយូនណាន ហើយបានសម្តែងនូវចំណាប់អារម្មណ៍របស់ខ្លួនថា យើងទាំងអស់គ្នាបានជាប់ចិត្តទៅនឹងខេត្តយូនណានតាមរយៈការចូលរួមពិព័រណ៍ចិន-អាស៊ីខាងត្បូងនេះ ។

លោក ធី មូហាន (T Mohan) មកពីកាសែត ខ្មែរ ថែម "KHMER TIMES" បានសម្តែងនូវការស្រឡាញ់ចូលចិត្តចំពោះខេត្តយូនណានជាច្រើនលើកថា យូនណានពិតជាស្អាតណាស់។ នៅរដូវរងាឆ្នាំនេះខ្ញុំមុខជា នឹងនាំគ្រួសារខ្ញុំមកលេងទីនេះមិន ខាន។ លោកបន្តទៀតថា ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារពិព័រណ៍នេះមានទ្រង់ទ្រាយធំក្រៃលែង ហើយមានប្រទេស និងផលិតផលច្រើនបានចូលរួមពិព័រណ៍ ។



*អ្នកសារព័ត៌មានកម្ពុជា គង់ សិរីវ័ត្ត រូបខាងឆ្វេង កំពុងសិក្សាអំពីបច្ចេកវិទ្យា នៅពិព័រណ៍ចិន-អាស៊ីខាង ត្បូង លើកទី ៥ (រូបថតដោយ Liu Rong )*

នៅពេលឡើងជិះរថភ្លើងល្បឿនលឿន លោកគង់ សិរីវ័ត្ត អ្នកសារព័ត៌មានមកពីទីភ្នាក់ងារសារព័ត៌មានកម្ពុជាបានយកទូរស័ព្ទដៃមកថតរូបភ្លាមៗ ។ លោកបានបញ្ជាក់ថា នេះជាលើកទី១ដែលខ្ញុំជិះរថភ្លើងល្បឿនលឿន ។ ពិតជាលឿនណាស់ ! យើងធ្វើដំណើរបាន ៧០គីឡូម៉ែត្រតែចំណាយពេលត្រឹមតែ ២០នាទីប៉ុណ្ណោះ។ជាពិសេសយើងអាចសាកទូរស័ព្ទបានហើយមានម៉ាស៊ីនត្រជាក់ លើរថភ្លើង ។

ឆ្នាំនេះជាខួបទី៦០ នៃការបង្កើតទំនាក់ទំនងការទូតចិន និងកម្ពុជា ។ នៅពេលបញ្ចប់កម្មវិធីយកបទសម្ភាសន៍ អ្នកសារព័ត៌មានខ្មែរបានសម្តែងនូវក្តីសង្ឃឹមដ៏ល្អបវរចំពោះការរីកចម្រើននៃទំនាក់ទំនងមិត្តភាពចិននិងកម្ពុជាថា សូមបូកសរុបដោយប្រើពាក្យចាស់មួយម៉ាត់ គឺសូមជូនពរឱ្យមិត្តភាពចិន-កម្ពុជាស្ថិតស្ថេរចីរកាល!

## ខេត្តយូនណានសម្រេចបានការទូទាត់ប្រាក់យាន់ចិនឆ្លងដែនជាង៤សែនលានយាន់

តាមប្រភពព័ត៌មានពីពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី៥ដែលរៀបចំពីថ្ងៃទី ១៤ ដល់ទី ២០ ខែមិថុនា ឆ្នាំ២០១៨ ក្នុងក្រុងគុនមីងនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅខេត្តយូនណានបានទទួលការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការទូទាត់ប្រាក់យាន់ចិនឆ្លងដែនដែលបានសម្រេចនូវទំហំទូទាត់សរុបជាង ៤ សែនលានយាន់ ។ ក្នុងនាមជាអ្នកជំរុញ និងអ្នកចូលរួមសំខាន់ក្នុងការធ្វើកំណែទម្រង់ផ្នែកហិរញ្ញវត្ថុតាមតំបន់ព្រំដែនធនាគារប្រជាជនចិនសាខាគុនមីងបានខិតខំយ៉ាងសកម្មដើម្បីបំពេញការងារហិរញ្ញវត្ថុមួយចំនួនធំ ដូចជាបង្កើតច្រកប្តូរប្រាក់ថៃនិងវៀតណាម សម្រេចការដឹកជញ្ជូនប្រាក់ចិននិងឡាវដោយឆ្លងដែន និងកសាងមជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងនឹងរូបិយវត្ថុក្លែងក្លាយឆ្លងដែនប្រចាំក្រុងគុនមីង ។ ក្នុងចំណោមប្រទេស និងតំបន់ចំនួន ៣៩ ដែលធ្វើការទូទាត់ប្រាក់យាន់ចិនឆ្លងដែននៅខេត្តយូនណានទំហំទូទាត់នៃប្រទេសចំនួន ៣ (មីយ៉ាន់ម៉ា វៀតណាម និងឡាវ) មានចំនួនស្មើនឹង៦៥,០៤ ភាគរយ នៃទំហំទូទាត់សរុបរបស់ប្រទេសទាំង ៣៩ ៕

**(ស៊ីនហួចិន)**

## សៀងគួជីងស្រុកកំណើតស្វារោមមាសយូនណានអច្ឆរិយៈ

នៅថ្ងៃទី ១៣ ខែមិថុនា វេលាម៉ោង៩ព្រឹក លោក យូ ជីនហួ អ្នកថែរក្សាព្រៃឈើកំពុងច្រៀងចម្រៀងប្រជាប្រិយជាភាសាជនជាតិលីស៊ូ ដែលជាសញ្ញាមួយសម្រាប់ទាក់ទាញឱ្យសត្វស្វារោមមាសមកស៊ីចំណី ។ នេះជាទិដ្ឋភាពមួយដែលកើតឡើងនៅឃុំសៀងគួជីងស្រុកវៃស៊ីមណ្ឌលស្វយ័តជនជាតិទីបេតទីឈាងនិងមានទីតាំងស្ថិតនៅក្នុងតំបន់អភិរក្សធម្មជាតិថ្នាក់ជាតិភ្នំព្រឹលប៉ៃម៉ាខេត្តយូនណាន ។

លោកទើបច្រៀងតែប៉ុន្មានម៉ាត់ក៏ស្តាប់ឮសត្វស្វាស្រែកតបមកវិញថា "ជីជី អឺនអឺន" រួចហើយពួកវាបានបង្ហាញខ្លួនមកស៊ីចំណីភ្លាមៗ ដែលមនុស្សជាតិផ្តល់ដល់ពួកវា ។

ស្វារោមមាសជាសត្វកម្រឃើញដែលទទួលការអភិរក្សក្នុងតំបន់អភិរក្សធម្មជាតិថ្នាក់ជាតិភ្នំព្រឹលប៉ៃម៉ា ។ ដោយសារបានទទួលនូវការថែទាំច្រើនពីមនុស្សជាតិ ពួកវាលែងខ្លាចមនុស្សហើយ ។ សព្វថ្ងៃ ហ្វូងស្វានៅសៀងគួជីងមានសត្វស្វាជាង៧០ ក្បាល ដែលបែងចែកជាគ្រួសារស្វាចំនួន១២ក្នុងនោះមានគ្រួសារមួយសុទ្ធតែជាស្វាឈ្មោល។ កញ្ញា វ៉ាង ឈុនភីង និស្សិតអនុបណ្ឌិតនៃសាកលវិទ្យាល័យរុក្ខកម្មនិរតីចិនយកកែវយឺតសង្កេតមើលហ្វូងស្វាបណ្តើរនិយាយជាមួយអ្នកកាសែតបណ្តើរថា ហ្វូងស្វារោមមាសយូនណានបែងចែកឋានៈច្បាស់លាស់ ។ និយាយជាទូទៅគ្រួសារមានតែស្វាឈ្មោលខ្លាំងជាងគេមានសមាជិកច្រើនបំផុតហើយមានឋានៈខ្ពស់ជាងគេក្នុងហ្វូងស្វា ។

សព្វថ្ងៃស្វារោមមាសបានទទួលការយកចិត្តទុកដាក់កាន់តែច្រើនពីមនុស្សជាតិ ដូច្នេះហ្វូងស្វាមានចំនួនស្វាកាន់តែច្រើន និងបានបង្កើតជា "សហគមន៍ស្វា" ដ៏ធំមួយ ៕

**ដោយ ឈីន ឈួងយី**



*សត្វស្វារោមមាសដែលគេចាត់ទុកថា ជាសត្វអច្ឆរិយមួយ នៅលើភ្នំព្រិល ប៉ៃម៉ា (រូបថតដោយ Chen Fei )*

## ពន្លាពិព័រណ៍តំបន់តៃវ៉ាន់ សិប្បកម្មច្នៃប្រឌិតថ្មីទាក់ទាញក្រសែភ្នែកពីអ្នកទស្សនា

ក្នុងពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី៥ដែលរៀបចំពីថ្ងៃទី១៤ដល់ទី២០ ខែមិថុនា ឆ្នាំ២០១៨នេះ ផលិតផលច្នៃប្រឌិតផ្នែកវប្បធម៌ដ៏ច្រើនបានត្រូវដាក់តាំងពិព័រណ៍នៅពន្លាពិព័រណ៍តំបន់តៃវ៉ាន់ ។ ផលិតផលទាំងនោះបានទាក់ទាញក្រសែភ្នែកពីអ្នកទស្សនាជាតិ និងអន្តរជាតិតាមរយៈគំនិតច្នៃប្រឌិតអំពីវត្ថុសិប្បកម្មមាសឈើ ដី និងថ្មជាដើម ។

ម្ចាស់រោងសិប្បកម្ម "ថាវស៊ី" ជាប្តីប្រពន្ធមួយគូ ដែលមកពីតំបន់តៃវ៉ាន់ ។ ពួកគាត់បានយកសិប្បកម្ម "ពែងធានមូ" ដែលជាសិប្បកម្មពិសេសនៅរជ្ជកាលសុងប្រទេសចិនទៅច្របាច់បញ្ចូលគ្នាជាមួយធាតុផ្សំសិល្បៈ ទំនើបដែលបានច្នៃប្រឌិត និងបង្កើតស្នាដៃ "កាដួស៊ីនប៉េ" នៅតំបន់តៃវ៉ាន់ ហើយបានទទួលពានរង្វាន់ "គំនិតច្នៃប្រឌិតវិចិត្រសិល្បៈចិន" ក្នុងពិព័រណ៍វប្បធម៌សិនជិន។ កញ្ញា លីន យីងយូ មកពី រោងសិប្បកម្ម "ថាវស៊ី" បានប្រាប់អ្នក កាសែតថា យើងបាននាំយកស្នាដៃថ្មីៗមកចូលរួមពិព័រណ៍ចិន-អាស៊ីខាងត្បូង។ ពណិខៀវលើវត្ថុពរ្សឺឡែន តំណាងឱ្យមហាសមុទ្រដែលបង្កប់នូវអត្ថន័យថា ក្នុងដំណើរនៃការកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ" វប្បធម៌ចិនដ៏ជ្រៅជ្រះនោះនឹងដើរឆ្ពោះទៅកាន់ពិភពលោកទាំងមូល ។

លោកស្រីលីន ជួសាន ម្ចាស់រោងសិប្បកម្ម "ភីនជីនកី" បានបញ្ជាក់ថា យើងខ្ញុំបាននាំយកមកស្នាដៃជាង២០០ហើយសង្ឃឹមថា នឹងអាចផ្សព្វផ្សាយចំពោះពិភពលោកទាំងមូល។ យើងមានជំនឿចិត្តលើអនាគតរបស់ខេត្តយូនណានក្នុងវិស័យឧស្សាហកម្មច្នៃ ប្រឌិតវប្បធម៌ ហើយសង្ឃឹមថានឹងអាច រួមសហការគ្នា និងផ្លាស់ប្តូរគំនិតជា មួយសារមន្ទីរ និងសិប្បករខេត្ត យូនណាន ។

ពាណិជ្ជករតៃវ៉ាន់ជាច្រើនបានប្រាប់អ្នកកាសែតថា យើងធ្លាប់ឮគេនិយាយអំពីសិប្បកម្មពរ្សឺឡែនជីនស្វយ និងសិប្បកម្មពរ្សឺឡែនខៀវរបស់ខេត្តយូនណានវប្បធម៌យូនណានពិតជាអស្ចារ្យណាស់!៕ **ដោយ ចាំង វិនគី**